Contacts :


Makara Kol makara.kol@chello.fr

Ossarath Kol famille.kol@wanado.fr

Savary Chhem-Kieth savaryck@hotmail.com


# ធម្មទេសនា

## បុគ្គល ៣ ពួក

រៀបរៀងដោយ


ភិក្ខុ ឋិន តេន ឥន្ទប្បញ្ញោ

## វិយោគកថា

**ឧបាសក គល់ ទូច** បានធ្វើមរណកាលទៅ នៅថ្ងៃអាទិត្យ ទី១៧ ខែកុម្ភៈ ឆ្នាំ២០០២ ត្រូវនឹងថ្ងៃ ៦កើត ខែផល្គុន - ឆ្នាំម្សាញ់ ព.ស.២៥៤៥ វេលាម៉ោង ៩ និង ១៥នាទីព្រឹក ក្នុងជន្មាយុ ៨៧ ឆ្នាំ ដោយរោគជរាភាព ។

មរណភាពរបស់លោក បានធ្វើឲ្យយើងខ្ញុំ ជាភរិយា ជាបុត្រធីតា ក្មួយៗ ចៅៗ និងចៅទួត មានការសោកស្តាយ អាឡោះអាល័យដល់រូបលោក ដ៏ធំធេងដែលពុំអាចរើសរកពាក្យណាមួយមកថ្លែងជំរាបបាន ។

ឆ្លៀតក្នុងឱកាសបុណ្យគម្រប់ ១០០ថ្ងៃ(២៦ឧសភា ២០០២) នេះ ខ្ញុំបាទគល់ មករា តាងនាមជាបុត្រនៃលោកនិងគ្រួសារទាំងអស់ សូមជំរាបជូនដោយត្រួសៗ នូវជីវប្រវត្តិសង្ខេបរបស់លោកឪពុក តាមកាសែ្សតថតសម្លេងរបស់លោក ដូចតទៅនេះ :-

## បោះពុម្ពចែកជាធម្មទាន

ក្នុងឱកាសបុណ្យ ១០០ ថ្ងៃត្រូវនឹង ២៦ ឧសភា ០២
នៃឧបាសក

# គល់ ទូច

ដោយការបរិច្ចាគទ្រព្យនៃក្រុមគ្រួសារ

និងការឧបត្ថម្ភពី

## វត្តពោធិវង្ស

101 . Bd de la République
77420 Champs - Sur- Marne
Tel-01-60-06-44-98
Fax-01-64-62-17-41

Mon grand-père c'est : Un sourire, Un cœur, Un homme, Un maître, Un professeur, Notre professeur, Un ami, Une épaule, Une oreille attentive, Un esprit serein, Une âme, Un mari, Un père, Un grand-père, Mon grand-père, Aujourd'hui mon grand-père est parti. C'est injuste de voir s'en aller un être si bon. Un cœur en or qui a passé sa vie à aider les autres Sons pour autant délaisser sa famille. Mon grand-père, il impose le respect. Mon grand-père, c'est de longues minutes dans ses bras, Sons parler, on se comprend. C'est lui qui m'a appris l'alphabet, mes premiers mots. Quand je serai grande, je voudrais être comme mon grand-père, C'est mon héros. Lok Euv, je suis fière de dire que tu es mon grand-père, Et un jour, toi aussi tu seras fier de moi.

Ta petite fille: **KOL LECKHENA**

Cet homme était la perfection réincarnée. C'était un merveilleux mari, un père attentionné, un grand-père adorable et un arrière grande-père exemplaire. Nul ne pourra atteindre la hauteur de sa sagesse. Sa gentillesse et son sourire étaient reconnus par un grand, nombre de personnes, qui porte à son égard un si grand respect et une estime incomparable. En effet, il était tellement honnête tellement loyal et tellement serviable. Il adorait son pays et y portait un grand dévouement car le bien être de sa patrie et de ses habitants était une de grandes préoccupations, sans pour autant oublier sa famille. Il était aimé de tous et c'est pour ça qu'il restera à jamais dans nos mémoires et dans nos cœurs. Cet homme était le plus grand de tous et cet homme était mon grand-père. J'aurais tant voulu te dire que je t'aime, que je suis fière d'avoir un grand-père comme toi et de porter ton nom. Tu peux te reposer en paix, car nous ne t'oublierons jamais.

**KOL BOPHARA** Ta petite fille



# ជីវប្រវត្តិសង្ខេប
# នៃឧបាសក គល់ ទូច

ខ្ញុំបាទ គល់ ទូច កើតនៅថ្ងៃ ១ ខែឧសភាឆ្នាំ ១៩១៥ នៅក្រុងភ្នំពេញ ។ ជាកូនលោក ឪពុកនាម កុច គល់ អ្នកម្តាយនាម ងួន ម៉ិច ។

ខ្ញុំមានបងស្រីម្នាក់នាម គល់ ជៀច ។

អាយុបាន ៨ឆ្នាំ មាតាបិតាខ្ញុំ លោកបានបញ្ជូនឲ្យខ្ញុំទៅស្នាក់នៅជាមួយព្រះគ្រូពញ្ញាន **វត្តបទុមវតី** ដើម្បីរៀនអក្សរខ្មែរ ។

អាយុបាន១០ឆ្នាំ បានចូលរៀនថ្នាក់កុមារដ្ឋាន ក្នុងសាលារាជការខេត្តកំពង់ឆ្នាំង ។ រីឯលោកឪពុកក៏បានទទួលតំណែងជាចាងហ្វាងសាលាដំបូងប្រចាំខេត្តកំពង់ឆ្នាំងដែរ។អ្នកម្តាយជាទីស្រឡាញ់របស់ខ្ញុំ លោកបានអនិច្ចកម្មចោលខ្ញុំ តាំងពីខ្ញុំមិនទាន់បានអាយុ ១០ ឆ្នាំម្ល៉េះ ។

លោកឪពុកខ្ញុំរៀបការ ភរិយាក្រោយ បានបុត្រ ៨ នាក់ទៀត គឺ :- ប្រុស ៣ និងស្រី ៥នាក់ ។

ខ្ញុំបាទរស់នៅខេត្តកំពង់ឆ្នាំង ពីឆ្នាំ ១៩២៥ រហូតដល់ ឆ្នាំ ១៩៣២ ។ ឆ្នាំ ១៩៣៣ ខ្ញុំបាទ បានប្រឡងជាប់ ចូលរៀននៅអនុវិទ្យាល័យព្រះ ស៊ីសុវត្ថិ ក្រុងភ្នំពេញ គឺជាអនុវិទ្យាល័យទីមួយរបស់ ប្រទេសកម្ពុជាយើង ។

ឆ្នាំ ១៩៣៥ អនុវិទ្យាល័យ ព្រះស៊ីសុវត្ថិ ក៏ប្តូរមកជាវិទ្យាល័យ វិញ ។ ឆ្នាំ ១៩៣៧ ខ្ញុំបានប្រឡងជាប់ សញ្ញាប័ត្ររួចហើយក៏សូមឲ្យលោកឪពុកចូលស្តីដណ្តឹង ប្អូនស្រីជីដូនមួយរបស់ខ្ញុំ ។ ខ្ញុំបានបន្តការសិក្សារហូតដល់ថ្នាក់ ទី ១ (Classe de Première ) តែប្រឡងបំណាច់ឆ្នាំធ្លាក់ ។ ឆ្នាំ១៩៣៩ ខ្ញុំបានឈប់រៀនហើយក៏សំរេច ចូលប្រឡងធ្វើ ជាលេខាធិការនៅក្រសួងលោកនាយករដ្ឋាភិបាល ប្រឡងបានជាប់ លេខ ១ ការប្រឡងប្រជែងនេះ ប្រព្រឹត្តឡើងជាលើកដំបូងបង្អស់នៅចុងឆ្នាំ ១៩៣៩នោះ ។



Lok Euv, tu es mon père, mon beau grand-père et ma référence.

Comme mon papa, tu faisais parti du clan des premiers forestiers khmers, les «Meprey », qui soignaient et protégeaient les forêts tropicales du Cambodge pour la génération future. Loyal et honnête, tu gérais les plantations d'hévéas et ramenais les devises au pays.

Ta vie était pratiquement brisée comme ton pays durant la période du génocide. Malgré cela, aucune puissance, aucun politicien n'avait pu t'acheter; tu cèdes ton Savoir mais pas ton Âme.

Tu ne vis que pour les autres, non seulement les membres de ta famille, mais aussi les déshérités du Cambodge. Combien de fois malgré ton âge, tu repartais dans les camps de réfugiés pour apporter ta mince contribution et rentrais dare-dare chez toi, démunis de tes effets personnels…Heureusement tu gardais sur toi ton chapeau, ton pantalon et ta chemise.

Lok Euv, tu ne changeras pas, tu es parti discrètement mais coquin, tout nu comme à ta naissance, laissant derrière toi ton chapeau, ta famille et ton pays …orphelins pour toujours.

Je t'adore.

Ry **Savary Chhem-Kieth**

J'écris présentement pour décrire le meilleur arrière-grand-père, le meilleur grand-père et l-un des meilleurs-pères (ça fait des longueurs mais bon…).

Lok Euv avait tout ce qu'un homme parfait aurait: une gentillesse sans limite, une intelligence hors du commun, il était généreux, calme et très fort ( il nous battait mon frère et moi au bras de fer ).Bien sûr, il avait des défauts ( personne n'est parfait ), mais je ne pourrai dire lesquels, pour la simple raison que je ne les jamais vu.
Lok Euv s'occupait toujours des autres, et il a connu plus de monde que je ne pourrai connaître en deux vies ( assez longues).On ne peut plus compter les gens qu'il a aidé. En plus il avait une mémoire phénoménale ( à rajouter aux qualités ): les contes, l'histoire, ses faits vécus…Rien ne sortait de sa tête. Sa vie ne tiendrait pas dans une centaine de livres ( gros comme des dictionnaires ! (Mais on va essayer de la tenir dans un).

Et pour finir, on pourra dire que toute sa famille ( et ses amis, ceux qu'il a aidés, et ceux qui l'ont aidé, et ses futurs arrière-arrière-petits-enfants… )penseront à lui très fort même s'il est parti.

**Sorivan Chhem-Kieth**, 2e arrière-petit-fils.



ខ្ញុំបាទចូលធ្វើការជាលើកដំបូងមាននាទី ជាលេខាធិការនៃខុទ្ទកាល័យរបស់លោក នាយករដ្ឋាភិបាល ។ ឆ្នាំ១៩៤០ ខ្ញុំបាទបានរៀបមង្គលការ ជាមួយគូដណ្តឹងរបស់ខ្ញុំនាង ឈ្មោះ អ៊ិត ទូច ហៅ ពាញ ជាកូនលោកអ៊ុំស្រី នុត សែង និងអ៊ុំប្រុស គឺ ឧកញ៉ាយោធានរិន្ទ,ភូឈួយ អគ្គមហាសេនា ងួន អ៊ិត ។

ខ្ញុំបាទនិងភរិយាខ្ញុំរស់នៅជាមួយគ្នាដោយសុខដុម ហើយបានបុត្រ ៦នាក់ គឺ :- ប្រុស ៥ នាក់ ស្រី ១ នាក់ ។

ឆ្នាំ១៩៤១ ប្រទេសកម្ពុជាបានបង្កើតសាលាឥណ្ឌូចិនផ្នែកខាងគង្គានិងរុក្ខា ជាលើកដំបូង ។ ខ្ញុំបាទបានប្រឡងចូលសាលានេះ ជាសិស្សច្បង ពេលប្រឡងចេញជាប់បានលេខ ១ ដោយខ្ញុំបាទប្រឡងបានជាប់លេខល្អ ខ្ញុំបាទមានសិទ្ធិជ្រើសរើសរកកន្លែងធ្វើការដែលខ្ញុំបានពេញចិត្ត ខ្ញុំបាទក៏សំរេចចិត្តមកធ្វើការនៅខេត្តកំពង់ឆ្នាំងមានមុខងារជាអ្នកត្រួតត្រាខាង រុក្ខា ។ អ្នកស្រុកចូលកាប់ព្រៃឈើធ្វើអុសដុតខុសច្បាប់ ភ្នាក់ងារ រុក្ខា ចាប់ឲ្យបង់ប្រាក់ពិន័យ អ្នកស្រុកក៏លើកគ្នា មកសុំពឹងពាក់ខ្ញុំបាទ

ឲ្យជួយដោះស្រាយឲ្យរួចខ្លួនពីពិន័យនោះ ដោយមានចិត្តអាណិតអាសូរអ្នកស្រុកផង ដោយគោរពច្បាប់ផង ខ្ញុំបាទសុខចិត្តចំណាយប្រាក់ខែផ្ទាល់ខ្លួនអស់ ៧ ខែជួយអ្នកស្រុកទាំងនោះ។ បន្ទាប់មកខ្ញុំបាទក៏សុំទៅរាជរដ្ឋាភិបាលផ្លាស់ទៅកាន់កាប់នៅដំបន់ឆ្លូងវិញ ។

ឆ្នាំ១៩៤៥ សង្គ្រាមលោកលើកទី២ ឆាបឆេះពេញពិភពលោក ជប៉ុនដេញចាប់បារាំងនៅ ប្រទេសកម្ពុជា ។ ក្នុងខេត្តកំពង់ចាម មានបារាំងនៅកាន់កាប់ដូចជាលោក Pierre ALLOUARD ដែលមានមុខងារធំណាស់ គឺត្រួតពេញប្រទេសកម្ពុជា និងវៀតណាម។

ខ្ញុំបាទត្រូវរាជរដ្ឋាភិបាលបញ្ជូនឲ្យមកមើលការខុសត្រូវជំនួសបារាំងនៅក្រុងកំពង់ចាមផង ខាងឆ្លូងផង ។ លុះសង្គ្រាមចប់ហើយ នាយខណ្ឌ័បារាំង ចូលមកកាន់មុខដំណែងរបស់ខ្លួនវិញ ។

ចំណែករូបខ្ញុំបាទក៏ត្រឡប់ទៅឆ្លូងវិញ ព្រោះលោកនាយកក្រសួងបានបង្កើតផ្នែក (Division) ឆ្លូងឲ្យទៅជាខណ្ឌ័ (Cantonnement) សំរាប់ខ្ញុំបាទតែម្តង ។

ឆ្នាំ១៩៤៦-១៩៤៨ នាយកក្រសួងបានប្រគល់ឲ្យខ្ញុំបាទត្រួត២



Le 17 février dernier s'est éteint un grand Monsieur, un Monsieur comme on n'en trouve malheureusement rarement dans un monde de plus en plus accaparé par des problèmes d'ordre matériel ou financier.

Non, ce Monsieur là avait d'autres soucis : il était passionné par la vie et oeuvrait chaque jour pour elle, lui donnant toutes ses forces, à travers son métier et tout son amour, à travers sa femme et ses enfants ou son pays.

Il savait aussi se battre pour ses valeurs et dénoncer l'immoralité sous toutes ses formes dont la corruption, une des grandes plaies de son pays contre laquelle il s'est élevé et est demeuré intraitable, ignorant l'appel de l'argent facile auquel beaucoup n'ont même pas essayé de résister.

En plus d'être passionné et grand défenseur de la vie cet homme était en plus généreux, attentif, respectueux, gentil, joyeux (j'avoue ne l'avoir jamais vu se mettre en colère), et il ne savait pas se prendre au sérieux.

Bref c'était un homme tel que la vie en crée quelques fois pour se défendre et pour montrer qu'elle vaut la peine d'exister, ce que je crois du fond du cœur.

Ce qui m'amène à dire combien je suis fier d'avoir eu un grand-père et modèle ce grand Monsieur et combien je suis triste qu'il nous ait quitté.

**Sokha KOL**

Tout cela, je n'aurai jamais osé lui dire. Car il était un exemple de modestie. Certainement qu'il aurait été touché…mais jamais il aurait admis tout ce que je viens d'écrire, à cause de sa trop grande humilité, de sa simplicité.

Comment décrire en peu de lignes une vie aussi remplie que fut celle de Lok Euv ? …L'homme aux mille récits, aux milles cœurs, aux mille cerveaux…aux mille chapeaux ! Une ligne pour décrire deux siècles de vie deux siècles d'amour et d'enseignement pour nous, son clan, pour nous ses descendants, ses héritiers.

La conclusion ? …Il vécut longtemps et heureux, entouré de ses nombreux enfants, de plusieurs petits-enfants et de quelques arrière-petits-enfants.

**Vanaka Chhem-Kieth**, 1er de trois arrière-petits-fils.

Ceux qui, de près ou de loin, ont eu la chance de le côtoyer diront sûrement de lui qu'il était d'une générosité sincère, d'une intégrité exceptionnelle et d'une fidélité rare. Qu'il avait un « charisme discret » tellement évident et un amour infini de sa femme, de sa famille, de son pays et de son peuple. Qu'il fut peut-être un des rares à essayer de se tenir droit dans une société sans repère ! Oui, sûrement. Pour moi, il sera toujours mon grand-père et mon modèle

**Nolsinavid YIM**, 1er petit-fils.



កន្លែងគឺ Cantonnement ក្រចេះស្ទឹងត្រែង ។ សូមជំរាប បញ្ជាក់ថាកាលនោះ ក្រចេះនិងស្ទឹងត្រែងមាន Cantonnement តែមួយទេ ។

ឆ្នាំ១៩៥០ រាជរដ្ឋាភិបាល បានបញ្ជូនខ្ញុំបាទឲ្យទៅធ្វើ Stage de Formation ( កម្មសិក្សា ? ) នៅទីក្រុងប៉ារីស ជាមួយគ្នាលោកជួប ហែល ។

ឆ្នាំ១៩៥១ ក្នុងខែកុម្ភៈខ្ញុំបាទត្រឡប់មកភ្នំពេញវិញ ។ ក្នុងឆ្នាំនោះរដ្ឋាភិបាល បារាំងបានប្រគល់ផ្នែកសេដ្ឋកិច្ច( Economie ) មកឲ្យខ្មែរកាន់កាប់វិញ ។ លោកជួប ហែល ដែលជាចាងហ្វាងក្រសួងរុក្ខា ក៏បានហៅខ្ញុំឲ្យទៅកាន់មុខងារជាចាងហ្វាងការិយាល័យក្រសួងសេដ្ឋកិច្ច ( Directeur de bureau du Ministère de l'économie ) ជាលើកដំបូងបង្អស់ក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ។

ឆ្នាំ១៩៥៣ ក្នុងរាជរដ្ឋាភិបាលថ្មីមួយ ឯកឧត្តមនាយករដ្ឋមន្ត្រីបានប្រគល់ដល់ខ្ញុំបាទនូវមុខងារ ជាប្រធាននៃឃ្លាំងទូទៅ(Chef des magasins généraux) ជំនួសបារាំងវិញ ។ ក្នុងមុខងារថ្មីនេះ

ខ្ញុំធ្វើបានចំនួន៥ ខែ ទើបរាជរដ្ឋាភិបាលទាញខ្ញុំបាទយកមកធ្វើជា Directeur du bureau du Ministère de l'économie Nationale វិញ រហូតដល់ឆ្នាំ១៩៥៥ ។

ឆ្នាំ១៩៥៥នេះហើយដែល គណៈបក្សសង្គមរាស្ត្រនិយមដឹកនាំដោយសម្តេចព្រះសីហនុ មានជ័យជំនះលើគណៈបក្សដទៃទៀត។ ព្រមគ្នានោះដែរក្រសួង រុក្ខា បានផ្លាស់ឈ្មោះមកជាក្រសួង រុក្ខា ប្រមាញ់ នេសាទ វិញ ។ សូមជំរាបថាត្រឹមរយៈ ពីឆ្នាំ១៩៥១ ដល់ឆ្នាំ១៩៥៥ ខ្ញុំបាទបំរើរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច ទាំងអស់៨នាក់ ។

ឆ្នាំ១៩៥៦-១៩៥៧ រដ្ឋាភិបាលបានចាត់ឲ្យខ្ញុំបាទទៅធ្វើជា Chef du Cantonnement ខាងរុក្ខានៅខេត្តពោធិសត្វនិងបាត់ដំបង ។ រួចហើយទើបទាញខ្ញុំបាទមកធ្វើជា Charge de l'institut de Recherche forestière នៅភ្នំពេញ ។

ចាប់ពីឆ្នាំ១៩៥៦ រហូតដល់ឆ្នាំ១៩៦០ ខ្ញុំបាទបានបង្រៀននៅសាលាកសិកម្ម ព្រែកលៀប បង្រៀនខាង Forestier ហើយបង្រៀនខាង Ecole des gardes forestiers នៅសាលាកំពង់ចាម។



**Il était une fois un grand homme**…Cette phrase qui en dit long, pourrait fort bien débuter la biographie d'un grand, d'un très grand homme : M. Kol Touch

Pour moi, c'était Lok Euv, pour d'autres Lok Ta ou tout simplement Euv. Quoi qu'il en soit, pour tout le monde il était une figure, un personnage.

Ce que je retiens de lui ? Tout et beaucoup. Mais étant plus jeune, une chose en particulier m'a fasciné. Comment une personne d'un âge aussi avancé peut-elle conserver en elle-même autant de savoir ? Et en continuer à en accumuler jusqu'à son départ ? Difficile à expliquer mis à part le fait que l'esprit de Lok Euv soit fort développé, du moins pour un humain moyen.

Je me souviendrais toujours des après-midi entiers passés à ses côtés, mes frères et moi, suspendus à ses lèvres alors qu'il nous racontait d'innombrables légendes et mythes, des aventures entre semi-homme et bêtes féroces ou encore des exploits de héros cambodgiens. Bientôt les histoires modernes, parleront d'un grand-père. Un grand-père à la mère Thérésa ou à la Gandhi. Ni plus, ni moins. Un fin conteur. Une vraie encyclopédie vivante.

L'histoire vivante du monde ? Il la raconte comme personne.
L'histoire du Cambodge ? C'est lui qui l'a écrite. Il est le Cambodge.

…/…

Un dicton populaire dit que *l'on ne choisit pas ses parents*; de ce fait, la première grande chance que j'ai eue dans ma vie est de t'avoir comme père.

Pour m'apprendre la vie, tu m'as élevé en m'inculquant le travail, l'autonomie tout en restant honnête, juste, intègre et humble, sans oublier ses propres origines, en pensant aux autres et surtout à ceux qui ont le plus besoin que l'on pense à eux. Tu m'as toujours mis devant mes propres responsabilités. Pour m'apprendre à nager, tu m'as balancé à l'eau  Pour, pour m'apprendre à faire des plats tu m'as mis à la cuisine, pour faire mes études en France j'ai du faire toutes les démarches administratives, etc., etc.…

Tu es resté fidèle à tes idées à travers tout les évènements que tu as vécu jusqu'à la fin de ta vie. Tu as su transmettre ton amour pour ton pays à tes petits enfants qui gardent ainsi un coin du Cambodge dans leur esprit grâce aux nombreuses histoires que tu leur as racontées.

Et comme dit une ou un autre dicton que *l'on récolte ce que l'on a semé,* nous sommes tous, tes enfants, tes petits-enfants et tes arrière-petits-enfants, en train de récolter ce que tus as semé pendant toute ta vie à savoir l'honneur et le respect pour notre famille. Maintenant que tu n'es plus là, nous te promettons de garder le cap que tu as tracé.

De ton fils **Ossarath**



នៅខាងសាលាចំការមន ខ្ញុំបាទបង្រៀនខាង Contrôleurs des Eaux et des Forêts ខាង gestion forestière រហូតដល់ឆ្នាំ១៩៦០។

ឆ្នាំ១៩៥៨ ខ្ញុំបាទទទួលនាទីជា Inspecteur des Services municipaux du gouvernement de la ville de Phnom Penh ។

ឆ្នាំ១៩៥៩ Le conseil des Ministres ទាញខ្ញុំបាទមកធ្វើការ Directeur du Bureau du Ministère de l 'agriculture ។

ឆ្នាំ១៩៥៩ នេះបារាំងទើបនឹងប្រគល់ Station de recherche sur le caoutchouc នៅតាប៉ាវមកឲ្យខ្មែរ ធ្វើជាក្រុមហ៊ុន Caoutchouc S-K-P-H ដែលមានរូបខ្ញុំបាទផ្ទាល់បានទៅទទួល la passation de service ការប្រគល់តំណែង ក្នុងនាទីជា "Président du Conseil d'administration. Ex-qualité " ។

ឆ្នាំ១៩៦១ ទើបរាជរដ្ឋាភិបាលប្រគល់មុខងារពេញលក្ខណៈឲ្យខ្ញុំបាទជាប្រធានអគ្គនាយកនៃក្រុមហ៊ុន ចំការកៅស៊ូនៅតាប៉ាវ ។ ខ្ញុំបាទកាន់កាប់មុខនាទីថ្មីនេះពីឆ្នាំ ១៩៦១ រហូតដល់ឆ្នាំ១៩៧៥ គឺឆ្នាំដែលប្រទេសកម្ពុជាធ្លាក់ចូលក្នុងកណ្ដាប់ដៃខ្មែរក្រហមតែម្ដង។

<u>*សូមរំលឹកថា*</u>

ឆ្នាំ១៩៦៧ សេដ្ឋកិច្ច ប្រទេសកម្ពុជាធ្លាក់ចុះដុនដាបយ៉ាងខ្លាំង សម្តេច ព្រះសីហនុ រៀបចំរដ្ឋាភិបាលពិសេសថ្មីមួយដែលរូបព្រះអង្គផ្ទាល់ជាអគ្គមគ្គុទ្ទេសក៍ សម្តេចសីហនុជា Premier Ministre Déléguéរីឯខ្ញុំបាទមាននាទីជា Secrétaire d'Etat de l'Agriculture ហើយទទួលភារៈជាប្រធានអគ្គនាយកចំការកៅស៊ូ នៅតាប៉ាវដដែល ។

ឆ្នាំ១៩៦៨ មានការផ្លាស់ប្តូររាជរដ្ឋាភិបាលគឺសម្តេចប៉ែន នុតឡើងជា Premier Ministre ជំនួសសម្តេចសឺនសានវិញ ។ រីឯខ្ញុំបាទមកកាន់នាទីតែមួយវិញ គឺប្រធានអគ្គនាយកក្រុមហ៊ុនចំការកៅស៊ូតាប៉ាវដដែល ។

ឆ្នាំ១៩៧០ មានរដ្ឋប្រហារមួយទម្លាក់សម្តេចព្រះសីហនុ ដឹកនាំឡើងដោយ អ្នកអង្គម្ចាស់សិរិមតៈ និងឯកឧត្តម លន់ ណុល ។ រដ្ឋាភិបាលថ្មីបានតាំងខ្ញុំបាទជា Commissaire Général à l'Hévéa Culture និងកាន់កាប់នាទី ជាប្រធាននៅតាប៉ាវដដែលព្រមទាំងគិតគូរពីរឿងផលដំណាំកៅស៊ូទាំងអស់ ។

ឆ្នាំ១៩៧៣ ដោយយល់ឃើញថា ប៉ុស្តិ៍ ( Poste ) ទើប






*ci-dessus, portrait de Lok Euv par :*
***Yavana chhem-Kieth** 3e arrière-petit- fils*

----- ----

Pour ses amis, ses anciens collègues de travail, ses anciens élèves, ses collègues d'association c'était l'homme le plus loyal, le plus éclairé, le plus viscéralement lié au sort du Cambodge, et à la couche la plus humble de son peuple, l'âme du pays, sans défense.

Mais pour nous, sa descendance, en plus de tout cela, c'était un mari, un père, un grand-père, un arrière-grand-père qui a su nous apprendre à affronter les adversités la tête haute toujours, à être honnête dans nos sentiments et nos actes.

Lok Euv, sois assuré que tout ton enseignement perdurera dans la famille, aussi élargie qu'elle saura.

**YIM Sidona**, sa fille unique**.**

Octobre 1991, tenu de la 2e Conférence de Paris, notre document fut prêt.
Le lendemain de la signature historique des accords de paix, les 4 délégations cambodgiennes, les principales délégations étrangères furent conviées par le groupe à une cérémonie officielle présidée par Monsieur KOL TOUCH
Objet: réception du 2e document de E.S.P.R.I.T Khmer intitulé
**" Contribution ouverte à études d'un plan de reconstruction et de développement du Cambodge d'après-guerre".**

***1992 : Association, loi 1901***
Le groupe jusqu'alors informel, devint une association sans but lucratif, loi 1901. Il avait précis le nom E.S.P.R.I.T Khmer Forum. Il avait élu Monsieur KOL TOUCH Président d'honneur, titre maintenu jusqu'à présent.

Monsieur KOL TOUCH avait participé activement à tous les colloques organisés par l'association. L'avant-dernier portait sur la pauvreté au Cambodge, sujet qui lui tenait le plus à cœur, car il partageait les malheurs de la population khmère qui souffrait encore, après le retour de la paix.
***« Mettra karuna »** étaient en effet les maîtres-mots de tout son existence.*

Fait à Besançon, le 2 Avril 2002

Le président de E.K.F.

Tan Boun Suy



បង្កើតមិនសូវមានផល ខ្ញុំបាទក៏សុំទៅរដ្ឋាភិបាល ឲ្យលុបផ្នែក Secrétaire Général d'hévéa culture ចោល ។ ខ្ញុំបាទទទួលមើលការខុសត្រូវត្រឹមតែ ចំការកៅស៊ូតាប៉ាវមួយប៉ុណ្ណោះ ។ ក្នុងឆ្នាំដដែលនេះ ទព័យួនយៀកណាម(យួន) និងពលខ្មែរក្រហមចូលពាសពេញនៅសល់តែរដ្ឋធានី ភ្នំពេញមួយប៉ុណ្ណោះ ។ ខ្ញុំបាទក៏លើកការិយាល័យមកតាំងនៅទល់មុខឃ្លាំងសាំង SHELL ក្បែររដ្ឋធានីភ្នំពេញដែរ ។

ឆ្នាំ១៩៧៥ ខ្មែរក្រហមវាយយកភ្នំពេញបាន គេមកកាន់កាប់ដោយបង្ខំឲ្យអ្នកភ្នំពេញចេញ ក្រៅក្រុងទាំងអស់ ។ ក្រុមខ្មែរក្រហមបានជម្លៀសគ្រួសារខ្ញុំបាទនិងខ្ញុំបាទ ឲ្យទៅនៅខាង”ចារធំ ឃុំ”ចុងជៀច” នៅចន្លោះ ”ដំប៉ែ ”និងក្រែក”ខេត្តកំពង់ចាម។

ថ្ងៃ៧មករា ១៩៧៩ ទ័ពយៀកណាមចូលពេញខេត្តកំពង់ចាមរហូតដល់ Lycée ហើយ ។ នៅកន្លែងខ្ញុំបាទគេជម្លៀសពួកខ្មែរក្រហមរត់បាត់អស់ ទើបពួកខ្ញុំបាទនាំគ្នាចេញមកវិញ ។

គ្រួសារខ្ញុំបាទ ព្រមទាំងបងប្អូនខ្មែរដទៃទៀត នាំគ្នាធ្វើដំណើរតាមផ្លូវជាតិ តម្រង់មកភ្នំពេញ ។ ដើរឈប់ៗអស់រយៈពេលជិត

មួយខែទើបមកដល់ច្រាំងចម្រេះ ត្រូវឈប់នៅទីនោះយ៉ាងយូរ ព្រោះទាហានយួនឃាត់ពួកយើងមិនឲ្យចូលភ្នំពេញ ។ ខ្ញុំបាទមកដល់ភ្នំពេញ ជាមួយគ្រួសារនៅដើមខែកុម្ភៈ មានគេនៅពេញទៅហើយ ។

ដើមខែមីនាឆ្នាំ១៩៧៩ ខ្ញុំបាទជួបពួក ”Journaliste” ពួកអ្នកកាសែតនៅឯច្រាំងចម្រេះ ដំបូងជួបលោក Jean françois ou J.Pierre Gallois ជា Agence France Presse ដែលពួកយួននាំឲ្យទៅមើលពួកភៀសខ្លួន ។ខ្ញុំបាទបានលួចខ្សិបៗជាមួយ M Gallois សុំផ្ញើសំបុត្រមួយមកកូនខ្ញុំបាទនៅ Paris ។ ខ្ញុំបាទផ្ញើដោយប្រុងប្រយ័ត្នបំផុត ព្រោះទាហានយួនហាមមិនឲ្យផ្ញើសំបុត្រចេញក្រៅទេ អត្ថបទ (article) របស់លោក Gallois នេះសរសេរនៅក្នុង ”Le monde” le 23 Mars 1979 មានឈ្មោះខ្ញុំបាទរួចជា ស្រេចនិយាយអំពីស្រុកខ្មែរ ។

ថ្ងៃ ៥ ឧសភា ១៩៧៩ ខ្ញុំបាទបានជួបនៅច្រាំងចម្រេះ នូវអ្នកកាសែត ២ រូបទៀត គឺ លោក Paul Nahon និង Jean Ray ដែលយួននាំទៅធ្វើ Reportage ការយកពត៌មានកាសែត



le premier document intitulé **"contribution ouverte pour la reconstruction du Cambodge d'après-guerre"**.
Ce document fut prêt en Juillet 1989, date de la première Conférence de Paris.
Ne faisant pas partie d'aucune des 4 factions cambodgiennes, le groupe n'avait pas été autorisé à y assister. Il faut absolument monter ce document aux participants de la Conférence.

Monsieur KOL TOUCH avait suggéré à TAN BOUN SUY et OM RITHOURN de le remettre aux délégations à leur sortie de la salle de réunion. Ce qui fut fait. Les délégations françaises, américaine et japonaise, agréablement surpris, avaient exprimé leur satisfaction, car à l'époque, à part notre groupe, personne ne s'était préoccupé à rassembler les données sur le Cambodge et à réfléchir sur les mesures à prendre pour l'après-guerre. C'est pourquoi, nous avions retrouvé comme par hasard, nos idées dans les résolutions de la 3e Commission (sur la Reconstruction), citées presque mot pour mot!

### *1991: 2e Conférence de Paris sur le Cambodge*

Ce succès avait permis de renforcer le groupe dont les membres étaient passés de 23 à 82…Répartis en 24 groupes, il travaillait pour élaborer un plan détaillé de tous les domaines de la reconstruction. Il avait fallu coordonner et gérer tout ce monde venant des horizons différents, avec des sensibilités différentes. Ce fut la tâche délicate de Monsieur KOL TOUCH qui, par son amabilité, sa sagesse, son patriotisme communicatif, y réunissait avec brio.

## Participation de Monsieur KOL TOUCH à la fondation et à l'essor de l'association E.S.P.R.I.T. Khmer Forum(E.K.F.) (1986-2002)

***1989 : fondation du groupe E.S.P.R.I.T.Khmer.***

L'avènement de Gorbatchev en URSS avait provoqué un séisme dans le monde. Le bloc de l'Est se lézardait : fortement impliqué en Asie du Sud-Est, il se décidait à plier bagage. Et, pour la première fois, un réel espoir de paix au Cambodge se dessinait à l'horizon. La diaspora cambodgienne engagée dans la lutte de libération du pays, doit maintenant se tourner vers la construction. Deux tâches majeures à accomplir:

1. Constituer un fond bibliographique sur le Cambodge: documents techniques, scientifiques, économiques nécessaires pour élaborer un plan de reconstruction;

2 Rassembler les ressources humaines: techniciens, scientifiques, économistes, éducateurs, sociologues jeunes et moins jeunes, ayant une expérience ou non au Cambodge.

Ces 2 tâches, Monsieur KOL TOUCH les avait parfaitement comprises. C'est sous son impulsion que fut fondé le groupe **E.S.P.R.I.T Khmer** (**E**: études; **S**: stratégiques; **P**: pour une planification; **I**: des infrastructures; **T**:techniques, scientifiques, économiques, sociales et culturelles)

***1989 : première Conférence de Paris sur le Cambodge***

Sur l'invitation de Monsieur KOL TOUCH, TAN BOUN SUY et FREDERIC LOEURNG se rencontrèrent à son domicile: le noyau dur du groupe fut créé. Il avait abouti à la formation d'une équipe pluridisciplinaire qui élabora en moins de 5 mois



នៅប្រាំងចម្រេះនេះ ។ លោក Paul nahon និងលោក Jean Ray បាននាំខ្ញុំបាទនិង ភរិយាខ្ញុំបាទជិះឡានយួនចូលទៅភ្នំពេញមើលផ្ទះខ្ញុំបាទ ។

ដោយសារ Reportage របស់លោក Paul Nahon នេះហើយ ទើបក្មួនខ្ញុំបាទនិងមិត្តភក្តិខ្ញុំបាទនៅប្រទេសបារាំង ដឹងថាខ្ញុំបាទនិងភរិយាខ្ញុំបាទនៅរស់ ។ ហើយជាពិសេស Mr Padirec Direteur Général de l'Institut de Recherche de Caoutchoue ដែលធ្លាប់ទាក់ទងនឹងខ្ញុំបាទជាញឹកនោះ លោកបានសរសេរសំបុត្រទៅយួន ដើម្បីសុំរូបខ្ញុំបាទ ។ ចំណែកខាងយួនបានមកយកខ្ញុំបាទទៅភ្នំពេញ ជាញឹកញាប់ណាស់ ដើម្បីសាកសួរពីក្មួនចៅរបស់ខ្ញុំនៅឯណាខ្លះ? ។ រួចហើយក៏បញ្ជូនខ្ញុំបាទទៅជួបរដ្ឋមន្ត្រីក្រុមក្រសួង គឺ លោកមាស សំណាង ”កុង្សីយ៏ ”ខាងចំការកៅស៊ូខាងសហជីព រួចបញ្ជូនខ្ញុំបាទឲ្យទៅធ្វើការនៅរោងចក្រសាមគ្គីរបស់ជប់ពីដើម ។

ថ្ងៃ១៩ ខែកក្កដា១៩៧៩ យួនឲ្យឡានមកដឹកខ្ញុំទៅជួបលោកមាស សំណាង លោកមាស សំណាងនាំខ្ញុំបាទទៅជួបកែវ ចិន្តា

រដ្ឋមន្ត្រីក្រសួងឃោសនាការថ្មី និងមុខងារមួយទៀតជាចាងហ្វាងតុលាការរាស្ត្រ ( Directeur du tribunal populaire ) ដែលយួនបង្កើតឡើងសំរាប់កាត់ទោសពួក ប៉ុល ពត ។ ចំណែករូបខ្ញុំបាទលោកហេង សំរិន បានតែងតាំងជា Accessoire suppléant du tribunal populaire ជាអ្នកជំនួសការបន្ទាប់បន្សំ នៅតុលាការរាស្ត្រឲ្យធ្វើការ នៅភ្នំពេញសំរាប់មើលសំណុំរឿង ( dossier) ដែលយួនរៀបចំស្រេចអស់ហើយដើម្បីកាត់ទោស ប៉ុល ពត និង អៀង សារី ។

ថ្ងៃ ៥ សីហា ១៩៧៩ យួនម្នាក់មកដឹកខ្ញុំបាទឲ្យទៅជួបលោកឡេឌឹកថរ ជាមេ ” B 68 ” គឺនៅថ្ងៃនោះមានប្រជុំពិសេសមួយ មានអ្នកបញ្ញាវន្តដែលនៅសេសសល់ ប្រហែលជា ៥០ នាក់ជាភ្ញៀវកិត្តិយស អង្គុយនៅលើវេទិកា ( Tribune ) ជាមួយលោក ”ឡេឌឹកថរ” និងលោក”ក្វាង”ជាមេ”B67” នៅភ្នំពេញមានអ្នកបកប្រែភាសាម្នាក់(Interprète) មានលោកស្រីផ្លេកភីរុណនិងពេទ្យស្រីខ្មែរម្នាក់ទៀតចូលរួមដែរ។

លោកឡេឌឹកថរ សួរខ្ញុំបាទថា ឥឡូវនេះកូនរបស់លោក សុំ



ទីស្រឡាញ់ឲ្យសោះ បើចង់ជួយស្រុក គឺជួយកន្លែងណាដែលជាចំណេះរបស់យើងទើបមានប្រយោជន៍ ។ ពាក្យទាំងអស់នេះ ហើយដែលធ្វើឲ្យនាងខ្ញុំមិនអាចបំភ្លេចបាន នៅចាំជាប់ក្នុងបេះដូងជានិច្ច ។

លោកគល់ ទូច វិញ្ញាណក្ខន្ធលោកបានចែកថានទៅមែនតែកេរ្តិ៍ឈ្មោះនៅអណ្តែតជាដរាប ៕

- នា រី -

✧ ✧ ✧ ✧ ✧

នាងខ្ញុំឈ្មោះនារីជាកូនប្រសារបស់ លោក គល់ ទូច នាងខ្ញុំសូមជំរាបអស់ លោក លោកស្រី ទាំងអស់ឲ្យបានជ្រាបថា លោក គល់ ទូច ជាវិរបុរសម្នាក់ ដែលស្រឡាញ់ប្រទេសជាតិ ជួយមនុស្សមិនប្រកាន់ឋានៈនិងពូជសាសន៍អ្វីឡើយ ឯចំណែកគ្រួសារកូនចៅទាំងអស់លោកតែងតែប្រៀនប្រដៅមិនឈប់ឈរ គឺឲ្យចេះនឹកគិតទៅដល់ស្រុកទេស ឲ្យចេះស្រឡាញ់បងប្អូននិងចេះជួយគ្នាទៅវិញទៅមក ទោះបីមានការពិបាកយ៉ាងណាក៏ដោយ ។

ពេលកាត់សក់ម្តងៗ លោកតែងតែហៅនាងខ្ញុំមកកាត់សក់ជូនលោក នាងខ្ញុំមិនមែនជាងកាត់សក់ទេតែដោយសារលោកចូលចិត្តនឹងស្រឡាញ់នាងខ្ញុំ នាងខ្ញុំក៏ប្រថុយកាត់សក់ជូនលោកទៅ ពេលកំពុងកាត់សក់ម្តង ។ លោកតែងតែនិយាយអំពីប្រទេសខ្មែរពីជំនាន់ដើមរហូតមកដល់ជំនាន់ឥឡូវប្រាប់នាងខ្ញុំជានិច្ចកន្លែងណាដែលនាងខ្ញុំមិនយល់ លោកក៏ខំពន្យល់នាងខ្ញុំឲ្យទាល់តែយល់ ។ មួយថ្ងៃមុននឹងលោកចែកឋានទៅ នាងខ្ញុំមានសំណាងបានទៅជួបលោក លោកបាននិយាយប្រៀនប្រដៅនាងខ្ញុំនិងប្តីនាងខ្ញុំ (មករា) ថាបើយើងបានសុខហើយកុំឲ្យភ្លេចអ្នកដីទៃនិងស្រុកដីជា



យកលោកទៅហើយ តើលោកទៅឬមួយគិតយ៉ាងដូចម្តេច ? ដំបូងខ្ញុំបាទឆ្លើយថា សូមនៅរយៈ ១ឆ្នាំ ឬ ២ឆ្នាំ ដើម្បីជួយស្តារប្រទេសកម្ពុជា ដែលកំពុងបាក់បែកអន្តរាយសម្បើមណាស់។ ល្អហើយ លោកឡេឌឹកថវ តបមកខ្ញុំវិញ ខ្ញុំនឹងយកលោកព្រមទាំងភរិយាលោកទៅព្រៃនគរ មើលថែទាំខ្លួននិងដាក់ធ្មេញ (ព្រោះកាលនោះខ្ញុំបាទបាក់ធ្មេញអស់ហើយ ) ។

គឺនៅខែកញ្ញា១៩៧៩ យួនដឹកខ្ញុំបាទនិងភរិយាទៅព្រៃនគរ ។ គេឲ្យពេទ្យម្នាក់និងអ្នកបកភាសាម្នាក់ទៅជាមួយគេ (យួន)យកខ្ញុំមកស្នាក់នៅ Ambassi hôtel នៅក្នុងបន្ទប់ពិសេសមួយ ចំណែកអាហារគេឲ្យចូលរួមបរិភោគជាមួយក្រុម Expert (អ្នកជំនាញការបរទេស) គេនាំខ្ញុំបាទនិងភរិយាទៅកាត់ខោអាវ ឲ្យពេទ្យដាក់ធ្មេញ ។ ហើយគេប្រាប់ខ្ញុំថា ” លោកអាចធ្វើអ្វីបានតាមចិត្ត ” ម្ល៉ោះហើយខ្ញុំគិតតែសរសេរសំបុត្រនិង ទូរស័ព្ទទៅកូននៅ Paris។

ដើមខែតុលា១៩៧៩ គេមកប្រាប់ខ្ញុំបាទថា ” លោកត្រូវអញ្ជើញទៅធ្វើការនៅភ្នំពេញវិញ ប៉ុន្តែយន្តហោះនៅសល់តែកន្លែងមួយគត់ខ្ញុំយល់ដឹងភ្លាមថាគេចង់បំបែករូបខ្ញុំពីភរិយាខ្ញុំហើយ

បើគេបំបែកខ្ញុំបាទបាន ប្រាកដជាគេមានគោលបំណងម្យ៉ាងមិនខាន ។ ខ្ញុំបាទក៏ឆ្លើយប្រកែកមិនព្រមទៅភ្នំពេញទេ ខ្ញុំសម្រេចចិត្តចេញមកបរទេសជួបកូនចៅវិញ។ ពួកយួនគេចង់ទុកខ្ញុំឲ្យនៅធ្វើការជាមួយគេ មែនទែន ។ ភរិយាខ្ញុំបាទប្រាប់គេវិញថា ” ខ្ញុំទាំងពីរនាក់មានវ័យចាស់ជរាហើយ ហើយឈឺច្រើនណាស់ ខ្ញុំសុំចេញទៅស្រុកបារាំងមើលខ្លួនសិន បើប្រទេសជាតិត្រូវការ ខ្ញុំនឹងមកជួយស្រុកខ្ញុំវិញ ។ បន្ទាប់ពីការសន្ទនាគ្នាអស់មួយរយៈធំជាមួយលោកក្វាងមេធំរួចមក គេប្រាប់ខ្ញុំថា ឥឡូវនេះគេរៀបចំផ្ទះមួយនៅ quartier général មានទឹកភ្លើង មានមនុស្សបំរើ ទុកឲ្យខ្ញុំនៅខ្ញុំក៏មិនព្រមនៅ រួចគេក៏ឲ្យខ្ញុំត្រឡប់មកផ្ទះវិញនៅថ្ងៃមួយគេមកហៅខ្ញុំទៅជួបលោកក្វាង ។ ក៏ប្រាប់ខ្ញុំថា អ្នកឯងត្រូវចេញទៅស្រុកបារាំង ប៉ុន្តែសូមកុំនិយាយជាមួយអ្នកកាសែត ចំនួន ៦ខែ។ លោកហ៊ុន សែន បានប្រាប់ខ្ញុំថា លោកឲ្យគេរៀបចំសំបុត្រស្នាមឲ្យខ្ញុំរួចហើយនៅព្រៃនគរ ។

មកដល់ស្រុកបារាំងទើបខ្ញុំបាទបានដឹងច្បាស់ថា ដោយសារការកៀបសង្កត់របស់កូនស្រីខ្ញុំបាទ គឺ សីដូណា នាងបានធ្វើ



ក្រោយនៃជីវិតថ្វីត្បិតតែសុខភាពលោកទ្រុឌទ្រោមក៏ដោយ លោកខំឲ្យជីវិតរបស់លោកមានប្រយោជន៍សំរាប់ស្រុកខ្មែរយើង។ គ្រប់ទីកន្លែងដែលខ្ញុំបានទៅដល់កេរ្តិ៍ឈ្មោះដ៏ល្អរបស់លោកតែងតែគេនិយាយគ្រប់ៗមាត់ ពាក្យមួយឃ្លាដែលលោកតែងតែពោលគឺយើងមិនអាចទ្រផែនដីម្នាក់ឯងរួចទេ ក៏ប៉ុន្តែបើមានតែយើងម្នាក់នោះទ្រផែនដីក៏អាចស្រាលមួយចំណែកតូចដែរ យើងមិនត្រូវទុកពេលវេលាឲ្យកន្លងទៅគ្រាន់តែដកដង្ហើមចោលឥតប្រយោជន៍នោះទេ ។ សូមអ្នកឪទុកចិត្តលើកូនចុះពាក្យប្រដៅនិងបណ្តាំទាំងឡាយកូននឹងធ្វើតាមមិនឲ្យល្អៀងឡើយ ។

កូនប្រុសរបស់អ្នកឪ
ឡា. ( គល់ មករា )

ជនខ្មែរទាំងមូល ។

ក្នុងនាមនៃសមាគមអ្នកបច្ចេកទេសកសិកម្មខ្មែរ AMITAK យើងខ្ញុំសូមថ្លែងនូវសេចក្តីគោរពដ៏ជ្រាលជ្រៅចំពោះ វិញ្ញាណក្ខន្ធលោកពូ សូមចូលរួមមរណទុក្ខជាមួយលោកមីងព្រមទាំងគ្រួសារនិងសូមឧទ្ទិស សូមឲ្យវិញ្ញាណក្ខន្ធលោកពូបានទទួលនូវ បរមសុខក្នុងបរលោក កុំបីឃ្លាត ។

AMITAK

❖❖❖

អ្នកឪ ជាឪពុកម្នាក់ដែលខ្ញុំមានវាសនាជាកូន លោកមានចិត្តស្លូតបូតអត់ធ្មត់ លោកបានទូន្មានកូន ចៅ ចៅទួតឲ្យចេះជួយគ្នាទៅវិញទៅមក មិនយកកំហឹងការច្រណែននិងលោភលន់មកដោះស្រាយ លោកបានយកធម៌ព្រះពុទ្ធមកប្រៀនប្រដៅជានិច្ច ។

ចំពោះប្រទេសជាតិខ្មែរវិញ លោកជាវិរបុរសជាតិម្នាក់ដែលខ្ញុំមិនទាន់ជួបប្រទះនៅឡើយ ការស្មោះត្រង់មិនលោភលន់យកប្រយោជន៏ជាតិជាធំ យកកិត្តិយសឈ្មោះវង្សត្រកូលជាធំ លើសពីទ្រព្យធន ជួយទុក្ខធុរៈអ្នកដ៏ទៃពេលគេត្រូវការលោក។ ពេលចុង



សេចក្តីអំពាវនាវគ្រប់ទីកន្លែង ដូចជានាងបានឡើងទៅយំនៅ ក្នុង Télévision ស្ថានីយ៍ទូរទស្សន៍ ដើម្បីសូមឲ្យគេជួយធ្វើអន្តរាគមន៍ជួយយកខ្ញុំបាទនិងភរិយាចេញមក ។ មិនត្រឹមតែប៉ុណ្ណោះ កូនស្រីខ្ញុំបាទទូរស័ព្ទទៅកុងស៊ុល Consul យៀកណាមប្រចាំប្រទេសបារាំងជាញឹកញាប់ណាស់ ហើយកំញើញថា បើមិនឲ្យលោកឪលោកម៉ែខ្ញុំចេញទេ ខ្ញុំជាកូននឹងទៅលួចយកគាត់មកហើយ ដោយឃើញហេតុការណ៍យ៉ាងនេះ ក៏យួនមិនហ៊ានទុកខ្ញុំបាទនិងភរិយាតទៅទៀត ។

គឺនៅថ្ងៃទី ២១ ខែធ្នូឆ្នាំ១៩៨១ ខ្ញុំបាទនិងភរិយាបានមកដល់ទឹកដីបារាំង នៅចំណតយន្តហោះ មានអ្នកសាព៌តមានពីរនាក់ គឺលោក "Paul Nahon" លោក "Jean Ray" ព្រមទាំងគ្រួសារខ្ញុំមកទទួល ។ មករស់នៅស្រុកគេនេះជាលើកដំបូង មានពួក Planteurs និងពួកមេព្រៃ និង (L.G.L.A.) ? បានជួយឧបត្ថម្ភច្រើនណាស់ ។ ខាង ( IRCE )? ហៅខ្ញុំបាទឲ្យធ្វើការមានបៀវត្សមានលេខ sécurité sociale ។ លោក Rouland ក៏បានជួយសុំផ្ទះ H .L.M. ឲ្យ ដែលខ្ញុំបាទព្រមទាំង

គ្រួសារបានរស់នៅរហូតសព្វថ្ងៃនេះ ។

ឆ្នាំ១៩៩២ តាមរយៈ ” TOKTEN ” នោះគឺ Programne របស់ ” PNUD ” Programme des Nations Unies pour le Développement ខ្ញុំបាទបានទៅបង្រៀននិយាយពីព្រៃហើយនឹង ’Hévéa Culture រួចគេឲ្យខ្ញុំបាទជួយមើល កិច្ចការធ្វើច្បាប់ថ្មី សូមជំរាបបញ្ជាក់ថានៅឆ្នាំ១៩៥០ ខ្ញុំបាទជា Membre របស់គណកម្មការដែលកែប្រែច្បាប់មេព្រៃដែលមាន តាំងពីខ្មែរយើងបានឯករាជ្យហើយនោះ ។

## ខ្ញុំបាទនិងភរិយាខ្ញុំ ខាងផ្លូវសាសនាវិញ

ក្រៅពីកិច្ចការបំរើក្នុងរដ្ឋការនិងប្រទេសជាតិ ខ្ញុំបាទនិងភរិយាខ្ញុំក៏បានជួយឧបត្ថម្ភខាងផ្លូវសាសនាជាច្រើន ដូចធ្វើបុណ្យផ្កាប្រាក់ដើម្បីយកបច្ច័យសាងសាលារៀន ។ នៅភូមិមេព្រៃ នៅកំពង់រាំង ខ្ញុំបាទសង់សាលារៀនដើម្បីប្រមូលកូនអ្នកស្រុកពីភូមិរំចេក និងចុងកាត់មាត់ញក ក្នុងស្រុកមេមត់ឲ្យមករៀន ។ មិនត្រឹមតែឲ្យរៀនចេះអក្សរ ប៉ុណ្ណោះទេ បានបង្កើតជា Internet ប្រាកលុយ



ស្នងកសិកម្មក្នុងថានៈជារដ្ឋមន្ត្រី នៅក្នុងក្រុមហ៊ុនចំការកៅស៊ូនៅកំពង់ចាមក្នុងថានៈ ជាប្រធានអគ្គនាយក ក៏ដូចជានៅ ប្រទេសបារាំងដែលលោកពូបានមកស្នាក់នៅ លោកពូខំប្រឹងផ្សព្វផ្សាយឥតឈប់ឈរ នូវគំនិតស្នេហាជាតិដល់ខ្មែរគ្រប់រូប ។ ក្នុងសម័យកាលសព្វថ្ងៃនេះក៏ដោយ ទោះបីជាខ្យល់ជំនោរនៃឯកត្តភាពជ្រុលនិយម Indevidualisme à l’éxtrême បោកបក់មកពីគ្រប់ទិសទីលើព្រលឹងខ្មែរយ៉ាងណាក៏ដោយ លោកពូ នៅតែប្រកាន់ខ្ជាប់នូវគោលគំនិតដ៏ថ្លៃថ្លា មានជាអាទិ៍ សេចក្ដីក្លាហាន យុត្តិធម៌ សុចរិតភាព និងគំនិតស្នេហាជាតិជានិច្ចឥតខ្ចោះ សំរាប់ឧទាហរណ៍ដល់ខ្មែរជំនាន់ក្រោយ ។

ក្នុងការបង្កើតសមាគមអ្នកបច្ចេកទេសកសិកម្មខ្មែរ AMITAK និងសមាគមអែសព្រៃខ្មែរ ហ្វរុម -EKF-ក្នុងឆ្នាំ ១៩៨៣ និង ៨៦ លោកពូខិតខំធ្វើការដោយឥតសំចៃកម្លាំង ដើម្បីកេណ្ឌ និងបំផុសជនរួមជាតិយើងនៅបរទេស ក្នុងគំនិតកសាងកម្ពុជាមួយដែលប្រកបទៅដោយយុត្តិធម៌-មនុស្សធម៌-សេរីភាព-អធិបតេយ្យភាព ដើម្បីនាំមកនូវសេចក្ដីសុខចំរើនដល់ប្រទេសជាតិ និងប្រជា

## អត្ថបទរបស់ សមាគមអ្នកបច្ចេកទេសកសិកម្មខ្មែរ

AMITAKក្នុងឱកាសបុណ្យរំឭក វិញ្ញាណក្ខន្ធគំរប់ ១០០ ថ្ងៃ នៃសពរបស់ **លោក គល់ ទូច** ប្រធានកិត្តិយសនៃសមាគម .

ខ្ញុំព្រះករុណា សូមក្រាបថ្វាយបង្គំព្រះសង្ឃគ្រប់ព្រះអង្គ ទ្រង់ឯកឧត្តម-លោកយាយតា-មីងមា-បងប្អូនទាំងអស់ជាទីគោរព ។

លោកពូជាទីស្រឡាញ់ និងជាទីគោរព

យើងខ្ញុំជួបជុំគ្នាថ្ងៃនេះដើម្បីប្រារព្ធធ្វើការរំឭកដល់វិញ្ញាណក្ខន្ធរបស់លោកពូ ដែលបានចែកស្ថានទៅហើយពីថ្ងៃអាទិត្យទី១៧កុម្ភៈ ២០០២ ក្នុងជន្មាយុ ៨៧ ឆ្នាំ នៅប៉ារីស។

មរណភាពរបស់លោកពូ ពិតមែនតែជាសភាវធម្មជាតិដែលសត្វលោកគ្រប់រូបទាំងអស់មិនអាចចៀសវាងបាន ប៉ុន្តែចំពោះយើងខ្ញុំ ជាការបាត់បង់ធំមួយ ដែលគួរឲ្យសោកស្តាយបំផុត ហើយដែលមិនអាចបំភ្លេចបានយ៉ាងងាយ ។ ។

ជីវិតទាំងមូលរបស់លោកពូ តាំងពីក្មេងវ័យរហូតដល់វ័យជរា នៅក្នុងអតីតកាល នៅនាយកដ្ឋានរុក្ខា និងប្រមាញ់ នៅក្រ



គ្នាជាមួយអ្នកស្រុកឆ្លងនោះជួយចិញ្ចឹមក្មេងៗ ដែលខ្វះខាតខ្សត់ខ្សោយ ។ បានធ្វើបុណ្យកឋិនទានរាល់ៗឆ្នាំ ឆ្នាំខ្លះធ្វើដល់ទៅពីរវត្ត បាននាំគ្នាបង្កើតវត្តនៅក្នុងកំពង់រាំង ភូមិមេព្រៃ រាល់ៗសីលនិមន្តលោកឲ្យសីល ប្រគេនចង្ហាន់ ជូនបាយទឹកដល់ចាស់ៗប្រុសស្រីពិសា ។ ឆ្នាំ១៩៦០ ខ្ញុំបាទនិងភរិយាខ្ញុំនាំគ្នា នាំអ្នកស្រុកបង្កើតវត្តមួយមុនគេបង្អស់នៅតាប៉ាវ ព្រមទាំងធ្វើកឋិនផ្កាប្រាក់ដាក់វត្តនោះផង ។

នៅស្រុកបារាំង បានធ្វើបុណ្យផ្កាប្រាក់ ២ ដង លើកទី ១ សំរាប់ជួយសង់ វត្តពោធិវង្ស កាលនោះបានចំណូលសម្បើមដែរជាង ៩ម៉ឺនហ្វ្រង្ក ។ រួចហើយក៏បានធ្វើជាមួយ អាមីតៈ ខ្ញុំបាទជា Membre Fondateur វត្តពោធិវង្សនេះ គឺជា ” ”Association pour le soutien du Bouddhistes KhmersA.S.B.K. ខ្ញុំបាទជា Membre fondateur ជាមួយទ្រង់ឥស្សរោ ។ បានធ្វើ បុណ្យផ្កាយកទៅសង់សាលាបាលីនៅស្តៅក្រោមជាមួយ AMITAK ក្រោយមកបានធ្វើបុណ្យនៅផ្ទះ ជាមួយគ្រួសារខ្ញុំប៉ុណ្ណោះបានចំណូល ២ ម៉ឺនដែរយកចូលវត្ត ។

ការធំដែល ភរិយាខ្ញុំនឿយជាងគេនោះគឺ :-

ការរៀបចំទទួលភ្ញៀវកិត្តិយសធំៗទាំងខ្មែរ ទាំងបរទេស មុននឹងភ្ញៀវអញ្ជើញទៅលោកចៅហ្វាយខែត្រវាយខ្សែរលួសឲ្យជាដំណឹងមុនឲ្យរៀបចំជាពិសេស ។ ភរិយាខ្ញុំចេះធ្វើម្ហូបចំណីអាហារល្អឆ្ងាញ់ពិសាប្រសើរណាស់។ ភរិយាខ្ញុំមានថ្វីដៃណាស់ក្នុងការទទួលភ្ញៀវ ព្រមទាំងបាន បញ្ជូនក្មេងៗឲ្យទៅរៀនរបៀបបំរើភ្ញៀវនៅក្នុង Hôtel Le Royal ផង ។ ព្រះសីហនុ លោកឲ្យសម្តេចញ៉ឹក ជូឡុង ជូនលោកស្រី និង លោក Phine Asisen (Avocat ជួយខ្មែរក្តី ព្រះវិហារមកខ្មែរវិញ ទៅលេងនៅតាប៉ាវ ភរិយាខ្ញុំជាអ្នករៀបចំទទួលភ្ញៀវនោះទាំងអស់ ។ មានភ្ញៀវផ្សេងៗដូចជាពួកមកពី Université Phillipine ពី Université de JAKARTA ព្រមទាំង délégation ចិន និង deputée Russe ក៏បានមកតាប៉ាវដែរ ។ មិនតែប៉ុណ្ណោះពួកនៅ ក្នុងស្រុកដូចជាពួកសិស្សនៅសាលាចំការដូងនាំសិស្សទៅរៀននៅតាប៉ាវ ឬពួកអស់លោកធំៗដូចជាសម្តេច ប៉ែន នុត និងលោកជំទាវ,ឯកឧត្តមលន់ ណុល និងលោកជំទាវ, អ្នកអង្គម្ចាស់សិរិមតៈ និងអ្នកអង្គ



ចេះរកទ្រព្យ ទុកជាគាប់ គ្រាន់បើដែរ
ក៏ប៉ុន្តែ នៅមានភ្នែក មួយរំខាន
ភ្លឺម្ខាង ខ្វាក់ម្ខាង មិនសមប្រាណ
គួរតែបាន ភ្លឺទាំងពីរ ទើបគ្រាន់បើ ។
កុំសប្បាយ ទាល់ភ្លេចខ្លួន នឹងភ្នែកមួយ
នៅមានព្រួយ ព្រោះកើតទុក្ខ ច្រើនទៀតតើ
ភ្លឺទាំងពីរ ទើបផុតទុក្ខ សុខប្រសើរ
ឥតអ្វីបើ ប្រៀបផ្ទឹមស្មើ បានសោះឡើយ ៕

ង . ភ .

# ខ្ញុំ ភ្នក បី

-✧-

ខ្វាក់ទាំងពីរ សែនងងឹត គិតមិនយល់
នាំអំពល់ ទល់តែទុក្ខ មុខក្រៀមក្រោះ
ជាមនុស្ស មិនឆ្លាតឆ្លុះ រកទ្រព្យសោះ
គ្មានរបស់ ទ្រព្យសម្បត្តិ ចិញ្ចឹមខ្លួន ។
ទាំងទានសីល រឹតតែខ្ជិល ភាវនា
មិនពុះពារ ខំនាំគ្នា ធ្វើខ្ជាប់ខ្ជួន
ចូលចិត្តធ្វើ អកុសល បាបផ្ទួន ៗ
ដឹកនាំខ្លួន ឲ្យរងទុក្ខ ឥតសុខឡើយ ។
ខ្វាក់ទាំងពីរ មិនល្អទេ នែ! លោកអ្នក
ត្រូវតែភ្ញាក់ រក្សាភ្នែក កុំកន្តើយ
យ៉ាងហោចណាស់ គង់បានមួយ គ្រាន់ធូរស្បើយ
មានទ្រព្យហើយ អាចកែខៃ ភ្នែកទៀតបាន ។



ម្ចាស់ក្សត្រី ក៏ត្រូវភរិយាខ្ញុំជាអ្នករៀបចំទទួលទាំងអស់ ។

ការសិក្សាភាសាអង់គ្លេស របស់ភរិយាខ្ញុំ ក៏ត្រូវអាក់ខានរៀន ដោយការទទួលភ្ញៀវមិនឈប់ឈរសោះ ។

សូមបញ្ជាក់ថាខ្ញុំបានធ្វើសមាធិវិបស្សនា ៨ដងនិងបំរើមួយដង ឯភរិយាខ្ញុំវិញ ធ្វើបាន ១៩ដងនិងបំរើ៤ដងនៅ Cente vipassana DHAMMA MAHI Le Bois Planté 89350 Louesme ។

ព្រមទាំងបានបំរើនៅពេលធ្វើវិបស្សនានៅវត្តស្វាយពពែ បាន ៤ ដងទៀត និងបានធ្វើនៅវត្តពោធិវង្ស បានមួយដងមួយកាល ហើយខ្ញុំនិងភរិយាខ្ញុំព្យាយាមធ្វើ សមាធិមួយថ្ងៃពីរដងជាដរាប ។

ធ្វើនៅថ្ងៃ ២៦ ឧសភា ឆ្នាំ ២០០២

-គល់ មករា-

ꕥꕥꕥ ✿ ꕥꕥꕥ

## នមត្ថុ រតនត្តយស្ស

**តយោមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ តយោ ។ អន្ធោ ឯកចក្ខុ ទ្វិចក្ខុ។**

ម្នាលភិក្ខុទាំងឡាយ បុគ្គល៣ពួកនេះ រមែងមាននៅក្នុងលោក ។ បុគ្គល ៣ពួក តើដូចម្ដេច ។ គឺ បុគ្គលមានភ្នែកងងឹត១ បុគ្គលមានភ្នែកម្ខាង ១ បុគ្គលមានភ្នែកពីរខាង ១ ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលមានភ្នែកងងឹត តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះគប្បីបាននូវភោគៈ ដែលខ្លួនមិនធ្លាប់បានក្ដី គប្បីធ្វើនូវភោគៈដែលខ្លួនបានហើយឲ្យចំរើនឡើងក្ដី ដោយចក្ខុមានសភាពយ៉ាងណា ចក្ខុមានភាពយ៉ាងនោះ មិនមានឡើយ មួយទៀត បុគ្គលគប្បីដឹងនូវពួកធម៌ជាកុសល និងអកុសល ដឹងពួកធម៌ដែលមានទោសនិងឥតទោស ដឹងពួកធម៌ថោកទាប និងឧត្ដម ដឹងពួកធម៌ដែលមានចំណែកទំនាស់គ្នាដោយអំណាចធម៌ខ្មៅ និងធម៌ស ដោយចក្ខុមានសភាពយ៉ាងណា សូម្បីចក្ខុមានសភាពយ៉ាងនោះ ក៏មិនមានដល់បុគ្គលនោះដែរ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **អន្ធោ** បុគ្គល



លោកបានសាងខ្លួនលោក បានចូលរួមសាងប្រទេសជាតិយ៉ាងច្រើនតាំងពីអតីតកាល រហូតដល់បច្ចុប្បន្ន ។ មិនមែនកសាងតែប្រទេសជាតិទេ សូម្បីតែសាសនា ក៏លោក គល់ ទូច បានកសាងយ៉ាងច្រើនដែរ ជាពិសេស លោក ជាអ្នកបដិបត្តិធម៌ រហូតដល់ចូលហ្វឹកហាត់ធ្វើ សមថៈ វិបស្សនា អស់រយៈពេលជាច្រើនឆ្នាំថែមទៀត ដែលមនុស្សជំនាន់គ្នា ថ្នាក់ប្រហាក់ប្រហែលគ្នាកម្រធ្វើដូចលោកបាន ។

ម្យ៉ាងទៀត សព្វថ្ងៃនេះ ខ្មែរយើងខ្លះ ជាព្រះសង្ឃក៏មាន ជាគ្រហស្ថ ក៏មាន កំពុងតែវង្វេង ឬ និយាយថាឆ្កួត ក៏មិនខុសក្នុងរឿង សមណសក្តិ ឯកឧត្ដម លោកជំទាវ ។ល។ ឧបាសក គល់ ទូច មិនវង្វេងដូចនោះទេ មិនក្រោធខឹងនឹងនរណា គេហៅលោកថាជាអ្វីៗនោះទេ ។ អ្នកឯទៀត គួរតែរៀនសូត្រតាមលោក គល់ ទូច ខ្លះៗទៅជាការប្រសើរណាស់ ។

**ភិក្ខុ ចិន ភេន ឥន្ទបញ្ញោ**

មិនទាន់ភ្លឺគ្រប់គ្រាន់ទេ ខំព្យាបាលបន្តិចទៅ កុំមានមានះច្រើនពេក ទិដ្ឋិមានះ មិនឲ្យប្រយោជន៍ដល់បុគ្គលណាទេ មានតែបន្ថែមទុក្ខ តាំងពីលោកនេះ រហូតដល់លោកខាងមុខទៀតតែប៉ុណ្ណោះ ។

លោក-អ្នក ពិនិត្យជាបុគ្គលម្នាក់ៗហើយ គប្បីពិនិត្យជាអង្គភាព ជាប្រទេសជាតិតទៅទៀត។ ប្រទេសជាតិយើងមានសម្បត្តិធម្មជាតិច្រើនណាស់ ឬ យ៉ាងហោចណាស់ ក៏ល្មមសាងប្រទេសជាតិ និងចែកចាយប្រជាជន ឲ្យមានជីវភាពរស់នៅសុខសប្បាយសមរម្យដែរ ។ ប៉ុន្តែសព្វថ្ងៃ យើងយ៉ាងម៉េច? ប្រទេសកសិកម្មឯទៀត គេដាំបន្លែមិនមែនគ្រាន់តែស៊ីទេ គេដាំលក់ទៅបរទេស យកប្រាក់រាប់ម៉ឺនលានចូលប្រទេសគេ សម្រាប់យើងវិញជាប្រទេសកសិកម្មដែរសព្វបើបន្លែទិញគេស៊ី សម្បត្តិរដ្ឋលក់ខ្មេចខ្ចីសូម្បីតែនគរវត្តក៏ជួលឲ្យគេដែរ បន្តិចទៀតអាចលក់ឲ្យគេក៏មិនដឹង ? តើខ្វាក់ ឬភ្លឺ ឬក៏ភ្លើ?

ចំពោះ ឧបាសក គល់ ទូច តាមដែលខ្ញុំព្រះករុណា អាត្មាធ្លាប់បានដឹង គឺលោកពិតជាមនុស្សមានភ្នែកភ្លឺទាំងពីរខាង ព្រោះ



មានភ្នែកងងឹត ។

ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានភ្នែកម្ខាង តើដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ គប្បីបាននូវភោគៈ ដែលខ្លួនមិនធ្លាប់បានក្តី គប្បីធ្វើនូវភោគៈ ដែលខ្លួនបានហើយឲ្យចំរើនឡើងក្តី ដោយចក្ខុមានសភាពយ៉ាងណា ចក្ខុមានសភាពយ៉ាងនោះ រមែងមាន ប៉ុន្តែ បុគ្គលគប្បីដឹងនូវពួកធម៌ជាកុសលនិង អកុសល ដឹងពួកធម៌ដែលមានទោស និងឥតទោស ដឹងពួកធម៌ថោកទាប និងឧត្តម ដឹងពួកធម៌ដែលមានចំណែកទំនាស់គ្នាដោយអំណាចធម៌ខ្មៅ និង ធម៌ស ដោយចក្ខុមានសភាពយ៉ាងណា សូម្បីចក្ខុមានសភាពយ៉ាងនោះ មិនមានដល់បុគ្គលនោះឡើយ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **ឯកចក្ខុ** បុគ្គលមានភ្នែកម្ខាង ។

ម្នាលភិក្ខុទាំងឡាយ ចុះបុគ្គលមានភ្នែកពីរខាង តើដូចម្តេច។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះគប្បីបាននូវភោគៈ ដែលខ្លួនមិនធ្លាប់បានក្តី គប្បីធ្វើនូវភោគៈដែលខ្លួនបានហើយឲ្យចំរើនឡើងក្តី ដោយចក្ខុមានសភាពយ៉ាងណា ចក្ខុមាន

សភាពយ៉ាងនោះក៏មាន មួយទៀតបុគ្គលគប្បីដឹងនូវពួកធម៌ជាកុសល និងអកុសល ដឹងពួកធម៌ដែល មានទោសនិងឥតទោស ដឹងពួកធម៌ថោកទាប និង ឧត្តម ដឹងពួកធម៌មានចំណែកទំនាស់គ្នាដោយអំណាចធម៌ខ្មៅនិងធម៌ស ដោយចក្ខុមានសភាពយ៉ាងណា សូម្បីចក្ខុមានសភាពយ៉ាងនោះ ក៏មានដល់បុគ្គលនោះដែរ ម្នាលភិក្ខុទាំងឡាយ នេះហៅថា **ទ្វិចក្ខុ** បុគ្គលមានភ្នែកពីរខាង ។

ម្នាលភិក្ខុទាំងឡាយ បុគ្គល ៣ ពួកនេះ រមែងមាននៅក្នុងលោក ។

សុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត
អន្ធសូត្រ ៤១-២៩-៦៦

ក្នុងព្រះសូត្រនេះ ព្រះពុទ្ធសម្តែងធម៌រឿង(ប្រធានបទ )ភ្នែក។ ភ្នែកក្នុងទីនេះ មិនមែនសំដៅយកមំសចក្ខុ ភ្នែកសាច់ ភ្នែកជាវត្ថុធាតុទេ សំដៅយក បញ្ញាចក្ខុ ភ្នែកគឺបញ្ញា ។ មានបញ្ញាចេះរកទ្រព្យសម្បត្តិបាន ចេះយកទ្រព្យសម្បត្តិដែលរកបានមកហើយធ្វើជាដើមទុន រកទ្រព្យសម្បត្តិឲ្យបានច្រើនឡើងទៀត នេះ



ឈ្មោះថាមានភ្នែកភ្លឺម្ខាង គឺ ភ្លឺផ្លូវលោក ។ មានបញ្ញា ដឹងបាប បុណ្យ គុណ ទោស កុសល អកុសល។ល។ ហើយលះអំពើអាក្រក់ ធ្វើតែអំពើល្អ បុណ្យកុសល នេះឈ្មោះថាមានភ្នែកភ្លឺម្ខាងទៀត គឺ ភ្លឺផ្លូវធម៌ ។ បុគ្គលណាមិនចេះរកទ្រព្យសម្បត្តិទាំងមិនចេះធ្វើបុណ្យកុសល បុគ្គលនោះឈ្មោះថា **អន្ធោ** មានភ្នែកខ្វាក់ទាំងពីរខាង ។ បុគ្គលណា ចេះរកទ្រព្យសម្បត្តិ ប៉ុន្តែមិនចេះធ្វើបុណ្យកុសល បុគ្គលនោះឈ្មោះថា **ឯកចក្ខុ** មានភ្នែកខ្វាក់ម្ខាង ភ្លឺម្ខាង មិនសូវល្អទេ ។ បុគ្គលណាចេះរកទ្រព្យសម្បត្តិផង ចេះធ្វើបុណ្យកុសលផង បុគ្គលនោះឈ្មោះថា **ទ្វិចក្ខុ** មានភ្នែកភ្លឺទាំងពីរខាង ល្អប្រសើរណាស់ ។

លោក អ្នក អានទាំងឡាយ យើងអានព្រះសូត្រនេះចប់ហើយយើងគួរតែពិនិត្យមើលខ្លួនយើងជាបុគ្គលម្នាក់ៗ តើយើងជាបុគ្គលមានភ្នែកភ្លឺទាំងពីរខាង ឬ មានភ្នែកភ្លឺតែម្ខាងខ្វាក់ម្ខាង ឬ ក៏មានភ្នែកខ្វាក់ទាំងពីរខាង ឲ្យពិន្ទុខ្លួនឯងទៅ ឲ្យយុត្តិធម៌ខ្លួនឯងទៅ ។ បើលោក អ្នក ពិចារណាទៅ ឃើញថា ភ្នែករបស់ខ្លួន